ព្រះគុម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះជាម្ចាស់បាន ត្រាស់ហៅបុរសម្នាក់



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson

កែសម្រួលដោយ៖ E. Frischbutter; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

នៅថ្ងៃមួយនោះ នៅក្នុងព្រះវិហាររបស់ព្រះជាម្ចាស់ មានបុរសម្នាក់
ឈ្មោះសាការី ដែលបំពេញមុខងារជាបូជាចារ្យ បានចូលទៅដុតគ្រឿង
ក្រអូប។ រីឯប្រ ជាជនយ៉ាងច្រើនកុះករនៅខាងក្រៅកំពុងអធិស្ឋាន។
រំពេចនោះ លោកមានការរន្ធត់ចិត្ត
និងភ័យខ្លាចយ៉ាងខ្លាំង។



ព្រោះមានទេវតារបស់ព្រះអម្ចាស់មួយរូបបានចូលមកឈរនៅខាងស្តាំអាសនៈ។ ទេវតានោះមានប្រសាសន៍ទៅកាន់លោកថា ៖

“កុំភ័យខ្លាចអ្វីឡើយ!”



“ព្រះជាម្ចាស់បានស្ដាប់ពាក្យអង្វររបស់លោកហើយ។ ភរិយារបស់
លោកនឹងបង្កើតកូនប្រុសមួយ ហើយលោកត្រូវដាក់ឈ្មោះថា យ៉ូហា
ន។ កូននោះនឹង បានពោពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធតាំងពីក្នុងផ្ទៃ
ម្ដាយ។ កូននោះនឹងបង្វែរចិត្តមនុស្ស
ជាច្រើនឲ្យវិលទៅរកព្រះជាម្ចាស់”។



ប្រជាជននៅខាងក្រៅរង់ចាំលោកសាការី ទាំងងឿងឆ្ងល់ណាស់។
ពួកគេនិយាយទៅកាន់លោកថា ៖
“សូមលោកមានប្រសាសន៍មកយើងខ្ញុំមកចុះ
លោកសាការី”។



ប្រជាជនទាំងនោះពុំដឹងថា ទេវតាកាព្រីយ៉ែលបានមានប្រសាសន៍ទៅ
កាន់ថា លោកនឹងទៅជាមនុស្សគ និយាយពុំកើតរហូតទាល់តែហេតុ
ការណ៍នោះបានសម្រេចតាមពេលកំណត់
ពីព្រោះតែលោកមិនជឿ
លើព្រះរាជសារដែលមកពីព្រះជាម្ចាស់។
លោកយល់ថា
ភរិយារបស់ចាស់ណាស់ហើយ
មិនអាចមានកូនបានទេ។



លោកសាការីត្រឡប់មកដល់ផ្ទះវិញ ហើយបានកត់ត្រាសេចក្ដីដែល
ទេវតាបានប្រាប់លោកទាំងអស់។ លោកស្រីអេលីសាបិត
មានសេចក្ដីអស្ចារ្យក្នុងចិត្ត ក្រៃលែង។
ពួកលោកទាំងពីរតែងតែអធិស្ឋានសូមព្រះ
ជាម្ចាស់ប្រទានឲ្យពួកលោកមានកូន។ តើពេលនេះ
វាពិតជាបានសម្រេចហើយមែនទេ?



លោកស្រីអេលីសាបិតបានដឹងជាក់ថា មានទារកកំពុងចាប់ទុំផ្ទៃគាត់
ហើយ។ លោកស្រីបានលើកតម្កើងព្រះជាម្ចាស់។ ថ្ងៃមួយនោះ
នាងម៉ារា ជាប្អូនស្រីជីដូនរបស់
លោកស្រីអេលីសាបិតបាន
មកសួរសុខទុក្ខគាត់។ នាងម៉ារា
ក៏កំពុងតែមានមានគ៌ភផងដែរ។



នៅពេលដែលនាងម៉ារា បានទៅភ្លាម ស្រាប់តែលោក
ស្រីអេលីសាបិតមានអារម្មណ៍ថា ទារកនៅក្នុងផ្ទៃនាង
ក៏បំរះឡើង។ លោកស្រីក៏បានពោរពេញដោយព្រះ
វិញ្ញាណដ៏វិសុទ្ធ។ លោកស្រីបានដឹងថា ទារកដែល
នៅក្នុងផ្ទៃនាងម៉ារា
គឺជាអង្គព្រះយេស៊ូគ្រិស្ទ។
អ្នកទាំងពីរបានលើកតម្កើង
ព្រះជាម្ចាស់ដោយអំណរ។



លោកស្រីអេលីសាបិត ក៏បានសម្រាលកូនដូចអ្វីដែលព្រះជាម្ចាស់បាន
សន្យាមែន។ បូជាចារ្យផ្សេងៗទៀតបានប្រាប់ថា ៖ “ត្រូវដាក់ឈ្មោះកូន
នេះថា សាការី ដូចឪពុករបស់គេទៅ”។
លោកសាការីនឹកឃើញព្រះបន្ទូលរបស់ព្រះ
ជាម្ចាស់។ លោកសាការី
បានសរសេរនៅលើក្តាមួយបន្ទះថា ៖
“កូននេះឈ្មោះ យ៉ូហាន”។
ក្នុងពេលលោកកំពុងសរសេរសេចក្តី
ទាំងនេះ លោកក៏អាចនិយាយ
បានឡើងវិញ។
លោកបានលើក
តម្កើងព្រះ
ជាម្ចាស់។



ពេលកុមារយ៉ូហានមានវ័យធំឡើង លោកមានលក្ខណៈដូចលោកអេលី
យ៉ា ជាអ្នកសំណព្វរបស់ព្រះជាម្ចាស់។
លោកយ៉ូហានបានប្រកាសប្រាប់ប្រជា
ជន ជាច្រើនថា ព្រះមេស្ស៊ី
នឹងយាងមកប្រទានព្រះពរដល់ពួកគេក្នុង
ពេលដ៏ឆាប់ខាងមុខ។ ពួកអ្នកដឹកនាំជំន
ជាតិយូដា ស្អប់លោកយ៉ូហានណាស់ ព្រោះ
លោកបានបង្គាប់គេថា ៖ “ចូរកែប្រែចិត្តគំនិត
ឈប់ប្រព្រឹត្តអំពើទៀតទៅ!”។



អ្នកខ្លះហៅលោកថា យ៉ូហានបាទិស្ត ព្រោះលោកតែងតែធ្វើពិធីជ្រមុជទឹកឲ្យប្រជាជន ដែលបង្ហាញថា ពួកគេពិតជាសោកស្ដាយចំពោះអំពើបាបដែល គេបានប្រព្រឹត្តពិតមែន។ ថ្ងៃមួយនោះ ព្រះយេស៊ូ បានយាងមកទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន។ លោកយ៉ូហានបានបដិសេធថា ៖ “គឺទូលបង្គំងណោះវិញទេ ដែលត្រូវទទួលពិធីជ្រមុជពីព្រះអង្គ”។ ប៉ុន្តែព្រះយេស៊ូ មានព្រះបន្ទូលថា ៖ “ចូរធ្វើចុះ!”។ ដូច្នេះហើយ លោកយ៉ូហានក៏ព្រមធ្វើពិធីជ្រមុជទឹកថ្វាយព្រះយេស៊ូ។



បន្ទាប់ពីព្រះយេស៊ូបានទទួលពិធី
ជ្រមុជទឹករួចហើយ,
លោកយ៉ូហានបានឃើញព្រះ
វិញ្ញាណដ៏វិសុទ្ធយាងចុះមក
សណ្ឋិតលើព្រះអង្គមាន
សណ្ឋានដូចជាសត្វព្រាប ដែល
ជាសញ្ញាសម្គាល់របស់ព្រះជា
ម្ចាស់ចំពោះអ្នកដែលព្រះអង្គចាត់
ឲ្យមក។ លោកយ៉ូហាន បានដឹង
ថា ព្រះយេស៊ូ ពិតជាព្រះបុត្រា
របស់ព្រះជាម្ចាស់។ លោកយ៉ូ
ហាន បានហៅព្រះយេស៊ូថា
កូនចៀមរបស់ព្រះជាម្ចាស់
ដែលដកបាបចេញពី
មនុស្សលោក។



លោកយ៉ូហាន បាននាំមនុស្សជាច្រើនឲ្យវិលមករកព្រះជាម្ចាស់។ ប៉ុន្តែ
ព្រះបាទហេរ៉ូឌ ដែលជាអ្នកដឹកនាំដ៏អាក្រក់ បានចាប់លោកយ៉ូហាន
ដាក់ក្នុងទីឃុំឃាំង។ ដោយព្រោះលោកបានប្រកាសថា ៖ “ការដែល
ទ្រង់យកព្រះនាងហេរ៉ូឌា
សត្រូវជាមហេសីរបស់ព្រះអនុជ
មកធ្វើជាមហេសីអង្គទ្រង់
គឺជាអំពើបាប”។



ព្រះបាទហេរ៉ូឌ បានជ្រាបពីសេចក្តីពិតនេះ។ ទ្រង់ក៏ជ្រាបដែរថា លោក
យ៉ូហាន ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ជាមនុស្សត្រឹមត្រូវ និង បរិសុទ្
ធ។ ប៉ុន្តែ ទ្រង់មិនចង់ចាកចេញពីអំពើបាបនោះទេ។



ចំណែកឯលោកយ៉ូហានវិញ
ក៏មិនឈប់ប្រកាស់ព្រះ
បន្ទូលប្រឆាំងនឹងអំពើបាបដែរ
បើទោះបីជាលោកត្រូវ
ជាប់ឃុំក៏ដោយ។

ព្រះបាទហេរ៉ូឌ បានរៀបពិធីលៀងសាយភោជន៍មួយយ៉ាងធំ ក្នុងឱកាសបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ។ ក្នុងឱកាសនោះដែរ បុត្រីរបស់ព្រះនាងហេរ៉ូឌាសបានចេញមករាំថ្វាយទ្រង់ទត។ ព្រះបាទហេរ៉ូឌ គាប់ព្រះហឫទ័យយ៉ាងខ្លាំង ទ្រង់មានបន្ទូលថា ៖ “សុំតាមចិត្តចុះ ទោះបីមួយចំហៀងនគរ ក៏ទ្រង់ឲ្យដែរ”។





ព្រះនាងតូចនោះក៏មាន
ការរំភើបព្រះទ័យណាស់
ក៏សួរថា ៖ “តើខ្ញុំម្ចាស់
ត្រូវទូលសុំអ្វីពីទ្រង់?”។
ព្រះមាតាដ៏អាក្រក់របស់
ព្រះនាង ព្រះនាម ហេរ៉ូ
ឌាស ដែលស្អប់លោក
យ៉ូហានដល់ឆ្អឹងផងនោះ
ក៏បានប្រាប់ព្រះនាងពីអ្វី
ដែលទូលសុំ! ការសុំ
នោះ គឺពិតជាអាក្រក់
ខ្លាំងណាស់!



ព្រះនាងតូចទូលព្រះបាទហេរ៉ូឌថា ៖ “សូម
ប្រទានក្បាលរបស់លោកយ៉ូហានបាទិស្ត
ដាក់លើថាស មកឲ្យខ្ញុំម្ចាស់”។ ព្រះរាជា
ព្រួយព្រះហឫទ័យក្រៃលែង ព្រោះទ្រង់បាន
ស្បថនៅចំពោះមុខភ្ញៀវទាំងអស់ជ្រុល
ហួសទៅហើយ ទ្រង់ក៏បញ្ជាឲ្យគេធ្វើតាម
ពាក្យរបស់ព្រះនាងតូចនោះ។
“គឺកាត់ក្បាលរបស់លោកយ៉ូហាន
ដាក់លើថាស ហើយយកមក
ថ្វាយព្រះនាងតូច”។
ពួកទាហ៊ានក៏ធ្វើតាម
បញ្ជារបស់ស្ដេច។

ជារឿងដ៏សោកសៅបំផុត មិត្តសម្លាញ់របស់លោកយ៉ូហាន ក៏បានយកសពនៃអ្នកបម្រើដ៏ក្លាហាន និង ស្មោះត្រង់របស់ព្រះជាម្ចាស់ទៅបញ្ចុះក្នុងផ្នូរ។ លោកយ៉ូហានបានបំពេញកិច្ចដែលព្រះជាម្ចាស់បានប្រគល់ឲ្យចប់សព្វគ្រប់។ ប្រហែលពួកគេក៏ដឹងជាក់ថា ព្រះយេស៊ូអាចនឹងកម្សាន្តឲ្យពួកគេបានស្បើយពីទុក្ខព្រួយបាន។



ព្រះជាម្ចាស់បានត្រាស់ហៅបុរសម្នាក់

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគុម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាកុស ៦; លូកា ១, ៣

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130


ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្ដីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣៖១៦